ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 13-Dec-2011, 09:36

CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១**

**ម៉ោង ០៩:០៩នាទី**

**សវនាការលើកទី៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ *(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន *(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន *(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស *(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោកស្រី នូស៊ីន សាកាវ៉ាទី

*(Ms. Nushin SAKARATI)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:៣៣]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងសូមជម្រាបជូនដល់ភាគី និងសាធារណជនបានជ្រាបថា តាមគម្រោងផែនការ និងតាមការប្រកាសជូនដំណឹងរបស់អង្គជំនុំជម្រះកាលពីម្សិលមិញថា កិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មសាក្សី ឡុង នរិន្ទ ត្រូវធ្វើបន្តនៅថ្ងៃនេះ ហើយជាការគោលបំណង និងថាអាចបញ្ចប់នូវថ្ងៃនេះបាន ប៉ុន្តែដោយហេតុថាថ្ងៃនេះតាំងពីយប់មិញមករហូតដល់ពេលនេះ ឡុង នរិន្ទ មានបញ្ហាសុខភាពធ្ងន់ធ្ងរដែលមិនអាចនឹងផ្តល់សក្ខីកម្មបាន។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចធ្វើសវនាករសម្រាប់ថ្ងៃនេះក្នុងការស្តាប់សក្ខីកម្មរបស់គាត់បានទេ។

សវនាការស្តាប់សក្ខីកម្មលោក ឡុង នរិន្ទ នឹងបន្តធ្វើនៅថ្ងៃអង្គារ ទី១៣ ខែធ្នូ ឆ្នាំ២០១១ ខាងមុខនេះ គឺសប្តាហ៍ក្រោយ។

ទីពីរ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនបានជ្រាបផងដែរថា សវនាការដែលគ្រោងធ្វើសវនាការនៅថ្ងៃ ចាប់ពីថ្ងៃអង្គារ ទី១៣ ខែធ្នូ ឆ្នាំ២០១១ ក្នុងការស្តាប់សក្ខីកម្មរបស់សាក្សី ឡុង នរិន្ទ នោះ។ នេះជាគម្រោងផែនការ តែប្រសិនបើបញ្ហាសុខភាពរបស់គាត់មិនអំណោយផលដល់អង្គជំនុំជម្រះក្នុងការស្តាប់សក្ខីកម្មរបស់គាត់ទេ ដោយស្ថានភាពដូចថ្ងៃនេះ នៅបន្តទៀតនោះ គឺអង្គជំនុំជម្រះសូមជម្រាបភាគីនិងសាធារណជនថា អង្គជំនុំជម្រះនឹងបន្តការសួរដេញដោលចំពោះជនជាប់ចោទ។ នេះសម្រាប់ចាប់ពីថ្ងៃអង្គារតទៅ។

[០៩:១១:៥០]

ដូច្នេះសូមភាគត្រៀមលក្ខណៈសម្បត្តិដើម្បី ឬឯកសារផ្សេងៗ ដើម្បីសម្រាប់បន្តការស្តាប់នូវសក្ខីកម្មរបស់សាក្សីរូបនេះ ឬក៏សួរដេញដោលចំពោះជនជាប់ចោទ។

ដូច្នេះ ភាគីនិងសាធារណជនអាចអញ្ជើញត្រឡប់ទៅកាន់គោលដៅដែលខ្លួនចង់ទៅ ឬលំនៅដ្ឋានរបស់ខ្លួនវិញបានហើយ ដោយសវនាការថ្ងៃនេះ អង្គជំនុំជម្រះមិនធ្វើទេ។ ហើយនិងសូមអញ្ជើញចូលរួមនៅក្នុងសវនាការដែលនឹងបន្តនៅសប្តាហ៍ក្រោយ ថ្ងៃទី១៣ ធ្នូ ឆ្នាំ២០១១ ចាប់ពីវេលាម៉ោងប្រាំបួនព្រឹក។

ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញចុះ ហើយឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ឲ្យបានមុនម៉ោងប្រាំបួនជាកំណត់៕

សូមអញ្ជើញទៅចុះ!

[០៩:១២:៥៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

*(សវនាការផ្អាកនៅម៉ោង០៩:១៣នាទី)*